ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា**
**ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ**

លេខៈ..០០៣/១៧...គ.ផ.ថ/ស.ជ.ណ

# សេចក្តីជូនដំណឹង
## ស្តីពីការបន្ថែមថ្ងៃ និងម៉ោងបម្រើសេវា ដល់ពលករកម្ពុជាដែលកំពុងធ្វើការនៅប្រទេសថៃ

ក្នុងគោលបំណងផ្តល់ភាពងាយស្រួលដល់ពលករកម្ពុជាធ្វើការនៅប្រទេសថៃ គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅនិងធ្វើការនៅប្រទេសថៃ សូមជូនដំណឹងដល់សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាដែលបានបញ្ជាក់អត្តសញ្ញាណធ្វើលិខិតឆ្លងដែន/លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) ជាមួយគណៈកម្មការ ជ្រាបថា ចាប់ពីថ្ងៃទី៦ ខែកុម្ភៈ រហូតដល់ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៧ គណៈកម្មការនឹង៖

១. បន្ថែមថ្ងៃបម្រើសេវាជូនបងប្អូនចំនួន ១ថ្ងៃក្នុង១សប្តាហ៍ គឺកើនពី ៥ថ្ងៃក្នុង១សប្តាហ៍ ទៅ៦ថ្ងៃក្នុង១សប្តាហ៍។

២. កែសម្រួលថ្ងៃឈប់សម្រាកនាថ្ងៃអាទិត្យ មកថ្ងៃ សុក្រវិញ។ ដូច្នេះថ្ងៃធ្វើការងាររបស់គណៈកម្មការគឺ ថ្ងៃសៅរ៍ អាទិត្យ ច័ន្ទ អង្គារ ពុធ និងព្រហស្បតិ៍។ តាមរយៈការកែសម្រួលនេះ បងប្អូនពលករអាចឆ្លៀតថ្ងៃឈប់សម្រាកចុងសប្តាហ៍ ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ មកដាក់ពាក្យស្នើសុំ និងទទួលសំណុំឯកសារពីគណៈកម្មការ។

៣. បន្ថែមម៉ោងបម្រើសេវាជូនបងប្អូនចំនួន ១ម៉ោង ក្នុង១ថ្ងៃ គឺកើនពី ៨ម៉ោងក្នុង១ថ្ងៃ ទៅ ៩ម៉ោងក្នុង១ថ្ងៃ ដោយចាប់បម្រើសេវាពីម៉ោង ៨:៣០នាទីព្រឹក ដល់ម៉ោង ៦:៣០ យប់ ក្នុងនោះឈប់សម្រាកអាហារថ្ងៃត្រង់ចំនួន ១ម៉ោង។

៤. ការិយាល័យបម្រើសេវាគឺស្ថិតក្នុងបរិវេណ "ស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍" ដែលមានអាស័យដ្ឋាន 518/4 Pracha Uthit Road, Soi Ramkamhang 39, Wanghonglang, Bangkok 10310, Kingdom of Thailand។

សាមីពលករ ដែលស្នើសុំដកសំណុំលិខិតពីគណៈកម្មការ ដើម្បីយកទៅទទួលបានភាពស្របច្បាប់ពីអាជ្ញាធរថៃ (បោះទិដ្ឋាការស្នាក់នៅ) ត្រូវយកមកតាមខ្លួននូវ ច្បាប់ថតចម្លងប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណព័ណ៌ស៊ីជំពូ) ចំនួន ១ច្បាប់ និងបង្កាន់ដៃទទួលពាក្យសុំផ្តល់លិខិតឆ្លងដែន ដែលចេញដោយក្រុមការងារចល័តរបស់គណៈកម្មការ។

សម្រាប់ពលករដែលមានលទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធអ៊ីធើណេត គឺអាចដាក់ពាក្យស្នើសុំដកសំណុំលិខិតនេះតាមរយៈគេហទំព័រ www.cambodianworker.net បាន។ សម្រាប់និយោជក ឬតំណាងនិយោជកស្របតាមច្បាប់ថៃ ដែលទទួលបានការប្រគល់សិទ្ធិពីពលករក៏អាចស្នើសុំដកសំណុំលិខិតតាមរយៈគេហទំព័រនេះបានផងដែរ។

គណៈកម្មការនឹងធ្វើការបើកផ្តល់ក្នុងរយៈពេល ១៤ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពេលទទួលបានសំណើសុំដកពីសាមីពលករ ឬនិយោជក។ យោងតាមការកំណត់ជាមួយភាគីថៃ កម្រៃសេវាក្នុងការបើកផ្តល់សំណុំលិខិតនេះគឺចំនួន ៩៥០បាត។

ចំពោះមុខគណៈកម្មការបាននឹងកំពុងពិភាក្សាជាមួយសមភាគីថៃ ដើម្បីកែសម្រួលនីតិវិធីបើកផ្តល់នេះឱ្យកាន់តែងាយស្រួល ទូលំទូលាយ និងខិតកៀកទៅដល់ទីតាំងរបស់បងប្អូនពលករ។ សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងទូរស័ព្ទលេខ +៦៦ ៨៦ ៧៩៩ ៩៩៥៧, +៦៦ ៩៤ ០៩២ ៥៩០៥, +៦៦ ៨២ ៧៧៧ ៧២១៥, +៦៦ ២ ៩៥៧ ៥៨៥១។

អាស្រ័យន័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសពលករកម្ពុជាដែលកំពុងស្នាក់នៅនិងធ្វើការនៅប្រទេសថៃជ្រាបជាព័ត៌មាន។

*រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៧*

**រដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការ**

**អ៊ិត សំហេង**